រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

043KH01A-01

ជំនួយសំរាប់ការអធិប្បាយ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៤៣

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

អធិស្ឋានទូលសូមអោយព្រះជាម្ចាស់ជួយអ្នក តាមរយៈមេរៀននេះ អោយចេះអធិប្បាយតាមរបៀបដែលមានប្រសិទ្ធិភាព ដើម្បីជួយកសាងក្រុមជំនុំរបស់អ្នកអោយរីកចំរើនឡើង ។

គោលដៅរបស់មេរៀននេះ គឺជួយអ្នកឱ្យចេះអធិប្បាយ និង ធ្វើឱ្យព្រះបន្ទូលព្រះជាម្ចាស់ទាក់ទងនឹងក្រុមជំនុំរបស់អ្នក ។ ដើម្បីអាចសំរេចគោលដៅនេះបាន អ្នកត្រូវធ្វើតាមជំហានទាំងនេះ :

១- ជ្រើសរើសប្រធានបទ ដែលមានប្រយោជន៍សំរាប់អ្នកស្តាប់

យើងជ្រើសរើសប្រធានបទ ដោយការអធិស្ឋាន ការគិតគូរពីសេចក្តីត្រូវការរបស់ក្រុមជំនុំ ព្រមទាំងសង្គម និង ការសិក្សាព្រះគម្ពីរ ។

កំណត់ចំណាំ :

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

☐ រៀបចំគម្រោងសេចក្តីអធិប្បាយមួយ ដែលអ្នកនឹងយកទៅអធិប្បាយ រួចប្រគល់ជូនគ្រូបង្ហាត់របស់អ្នកពិនិត្យ ។ ក្នុងគម្រោងនោះ ត្រូវមានសេចក្តីផ្តើមសំរាប់បញ្ជាក់ពីប្រធាន-បទ គោលគំនិតសំខាន់ៗ ដែលមានឧទាហរណ៍បំភ្លឺ ការអនុវត្ត និង សេចក្តីសន្និដ្ឋានដែលងាយយល់ ។

កំណត់ចំណាំ :

២ - អធិស្ឋាន

ដើម្បីអាចប្រកបទាក់ទងនឹងព្រះជាម្ចាស់បាន យើងត្រូវអធិស្ឋាន និង ទូលសូមឱ្យព្រះអង្គដឹកនាំ ។ យើងចង់អធិប្បាយអំពីសេចក្តីដែលព្រះជាម្ចាស់ប្រទានអោយយើង ។ យើងទុកចិត្តថា ព្រះជា-ម្ចាស់នឹងបើកសំដែងប្រាប់យើង នៅពេលដែលយើងអានព្រះគម្ពីរ ឬ ពិចារណាអំពីសេចក្តីត្រូវការរបស់ក្រុមជំនុំ ។



៣ - យល់ដឹង និង គិតគូរពីសេចក្តីត្រូវការរបស់ក្រុមជំនុំ

គ្រូគង្វាលខ្លះអធិប្បាយតែមិនបានលទ្ធផលទេ ពីព្រោះគ្រូគង្វាលទាំងនោះ មិនបានអធិប្បាយព្រះបន្ទូលអោយត្រូវចំសេចក្តីត្រូវការ និង ស្ថានភាពរបស់សមាជិករបស់ខ្លួន ។ យើងត្រូវស្គាល់សមាជិកក្នុងក្រុមជំនុំរបស់យើង ដើម្បីអាចដឹងពីសេចក្តីត្រូវការរបស់ពួកគេ ។



៥- គោលដៅរបស់សេចក្តីផ្តើមនៃសេចក្តីអធិប្បាយ គឺ :

☐ ពន្យល់អ្វីៗគ្រប់យ៉ាង ។

☐ ធ្វើអោយអ្នកស្តាប់ចាប់អារម្មណ៍ ចំពោះអត្ថន័យសំខាន់របស់សេចក្តីអធិប្បាយ ។

ការបញ្ជាក់ : សេចក្តីផ្តើមសំរាប់ធ្វើអោយអ្នកស្តាប់ចាប់អារម្មណ៍ ។

៦- គោលដៅនៃសេចក្តីសន្និដ្ឋានរបស់សេចក្តីអធិប្បាយ គឺ :

☐ ពន្យល់អ្វីៗទាំងអស់ឡើងវិញ ។

☐ បញ្ចប់ដោយលើកទឹកចិត្តអ្នកស្តាប់ និង ជំរុញឱ្យពួកគេអនុវត្តតាមសេចក្តីបង្រៀនក្នុងជីវិតរបស់ពួកគេ ។

ការបញ្ជាក់ : សេចក្តីសន្និដ្ឋានលើកទឹកចិត្តអ្នកស្តាប់ និង ជំរុញអោយពួកគេអនុវត្តតាមសេចក្តីបង្រៀនក្នុងជីវិតរបស់ពួកគេ ។

© Project WorldReach © SEAN

៣- <u>គោលគំនិតសំខាន់ៗ</u> ត្រូវជា :

☐ ឧទាហរណ៍អំពីប្រធានបទ ។

☐ សេចក្តីសំខាន់នៃអត្ថបទដែលទាក់ទងនឹងប្រធានបទ ។

ការបញ្ជាក់ : គម្រោងល្អត្រូវមានគោលគំនិតសំខាន់ៗ ជា សេចក្តីពិតសំខាន់ៗបំផុតរបស់វគ្គព្រះគម្ពីរ ។

៤- តើ<u>ឧទាហរណ៍</u>ណាមួយ ដែលល្អជាងគេអំពីគោលគំនិតសំខាន់ៗ ដែលពន្យល់ថា ព្រះហឫទ័យប្រណីសន្តោសមានន័យថា «ផលប្រយោជន៍ ដែលយើងមិនសមនឹងបានទទួល» ? ។

☐ ឧទាហរណ៍អំពីទូករបស់លោកណូអេ ។

☐ ឧទាហរណ៍អំពីកូនពៅដែលវង្វែង (ដែលបានឪពុកលើកលែងលែងទោស នៅពេលដែលកូនពៅនោះបានកែប្រែចិត្តគំនិត) ។

ការបញ្ជាក់ : យើងត្រូវបានព្រះជាម្ចាស់លើកលែងទោស និង បានទទួលព្រះពរដែលយើងមិនសមនឹងបានទទួល ដោយសារជំនឿរបស់យើង គឺមិនមែនដោយសារការប្រព្រឹត្តអំពើល្អទេ ព្រោះនេះជាព្រះហឫទ័យប្រណីសន្តោសសុទ្ធសាធ ។

តើយើងឃ្វាលក្រុមជំនុំ ដោយរបៀបណា ? (តើរបៀបឃ្វាលក្រុមជំនុំយើងណាមួយ ដែលប្រសើជាងគេ ?) ។

☐ ទៅសួរសុខទុក្ខពួកគេ និង ជជែកលេងជាមួយពួកគេ ។

☐ គ្រាន់តែអធិប្បាយព្រះបន្ទូលអោយពួកគេស្តាប់ ។

យើងត្រូវស្គាល់ និង ជជែកលេងជាមួយសមាជិកក្រុមជំនុំរបស់យើង ដើម្បី :

☐ អធិប្បាយព្រះបន្ទូលឱ្យត្រូវចំសេចក្តីត្រូវការរបស់ពួកគេ ។

☐ ទិតៀនពីកំហុសរបស់ពួកគេ ។

មុននឹងរៀបចំសេចក្តីអធិប្បាយ ត្រូវពិចារណាអំពីសមាជិករបស់ក្រុមជំនុំអ្នក :

- តើពួកគេត្រូវការជំរុញទ្រានដូចម្តេចខ្លះ ? ។
- តើពួកគេមានសេចក្តីត្រូវការអ្វីខ្លះ ? ។
- តើពួកគេសួរសំនួរដូចម្តេចខ្លះ ? ។
- តើខ្ញុំអាចណែនាំពួកគេ អោយមានសេចក្តីស្រឡាញ់កាន់តែខ្លាំងជាងមុន ដោយរបៀបណា ? ។

- តើផ្នែកណាខ្លះរបស់ជីវិតពួកគេ ដែលពួកគេត្រូវថ្វាយអោយព្រះគ្រីស្តដឹកនាំ កាន់តែច្រើនជាងមុន ? ។
- តើខ្ញុំអាចជួយពួកគេអោយចេះអធិស្ឋានដោយជំនឿខ្លាំងជាងមុន ដោយរបៀបណា ? ។
- តើខ្ញុំអាចជួយពួកគេអោយកាន់តែជឿជាក់ក្នុងចិត្តថា ពិតជាបានសង្គ្រោះ ដោយរបៀបណា ? ។
- តើខ្ញុំត្រូវជួយពួកគេអោយចេះប្រតិបត្តិតាមសេចក្តីបង្គាប់ណាខ្លះរបស់ព្រះគ្រីស្ត ? ។
- តើពួកគេត្រូវការយល់ដឹងកាន់តែច្បាស់ អំពីសេចក្តីបង្រៀនណាមួយរបស់ព្រះគម្ពីរ ឬ ពីកិច្ចការបំរើព្រះជាម្ចាស់ណាមួយ ? ។
- តើខ្ញុំអាចជួយពួកគេអោយសកម្មធ្វើកិច្ចការបំរើរបស់គ្រីស្តជនក្នុងសហគមន៍ជាងមុន ដោយរបៀបណា ? ។

គ្រូអធិប្បាយដែលមានចិត្តជាគ្រូគង្វាល ចេះមើលថែក្រុមជំនុំរបស់គាត់ ដោយហ្មត់ចត់ ហើយដឹងពីបញ្ហារបស់ពួកគេ ពីបំណងខ្លាំងក្លារបស់ពួកគេ ពីអំណោយទានរបស់ពួកគេ និង ពីការថ្វាយខ្លួនចុះចូលរបស់ពួកគេចំពោះព្រះជាម្ចាស់ ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- ដើម្បីជ្រើសរើសប្រធានបទរបស់សេចក្តីអធិប្បាយ :

- ☐ យើងត្រូវស្គាល់សមាជិក និង ស្ថានភាពរបស់ពួកគេ ។
- ☐ យើងត្រូវអធិស្ឋានទូលសូមអោយព្រះជាម្ចាស់ដឹកនាំ ។
- ☐ យើងពិនិត្យមើលព្រះបន្ទូលព្រះជាម្ចាស់ ។
- ☐ យើងធ្វើកិច្ចការទាំងអស់នេះ ។

ការបញ្ជាក់ : យើងត្រូវធ្វើកិច្ចការទាំងអស់នេះ ដើម្បីជ្រើសរើសប្រធានបទ ។

២- ចំពោះអត្ថបទព្រះគម្ពីរ យើងច្រើនតែបង្រៀនព្រះបន្ទូលបានល្អប្រសើរ ដោយ :

- ☐ ពន្យល់ និង អនុវត្តតាមតែវគ្គព្រះគម្ពីរមួយ ។
- ☐ ពន្យល់អត្ថបទច្រើន ដែលស្តីពីប្រធានបទនោះ ។

ការបញ្ជាក់ : បើសិនជាយើងបកស្រាយអត្ថបទច្រើនដែលទាក់ទងនឹងប្រធានបទតែមួយ នោះអាចធ្វើអោយអ្នកស្តាប់ធុញទ្រាន់ និង មានការភាន់ច្រឡំ ។ យកល្អ គួរតែបង្រៀនគោលគំនិតសំខាន់ៗរបស់ប្រធានបទមួយ ដោយប្រើវគ្គគម្ពីរមួយ ឬ ពីរ ដែលស្រាយបំភ្លឺអំពីប្រធានបទឱ្យបានច្បាស់ ។

៩- រៀបចំសេចក្តីសន្និដ្ឋាន

(ការបញ្ចប់)

សេចក្តីសន្និដ្ឋានសំខាន់ណាស់ ព្រោះគ្រូអធិប្បាយអញ្ជើញអ្នកស្តាប់អោយឆ្លើយតបទៅនឹងសេចក្តី ដែលគេបានស្តាប់ និង អនុវត្តសេចក្តីពិត នៅក្នុងអត្ថបទព្រះគម្ពីរនោះ ចំពោះការរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។ គ្រូអធិប្បាយធ្វើសេចក្តីសន្និដ្ឋានមួយខ្លី ដើម្បីលើកទឹកចិត្ត និង ជំរុញអ្នកស្តាប់អោយប្រតិបត្តិតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។

ឧទាហរណ៍ «ឥឡូវនេះ យើងដឹងថា ព្រះជាម្ចាស់បានប្រទានពរអោយយើង ដោយសារព្រះហឫទ័យប្រណីសន្តោសដ៏បរិបូណ៌របស់ព្រះអង្គហើយ ។ ហេតុនេះហើយ យើងត្រូវឈប់សង្ស័យទៅ ។ យើងត្រូវតែមានជំនឿ និង មានសង្ឃឹមកាន់តែរឹងមាំតទៅទៀត ។ យើងត្រូវធ្វើឱ្យអ្នកដទៃទៀតឃើញថា ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ បានបំផ្លាស់បំប្រែយើង ។ យើងនឹងសម្រួមចិត្តអធិស្ឋានមួយភ្លែត ដើម្បីអរព្រះគុណព្រះជាម្ចាស់រៀងៗខ្លួនចំពោះព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ ។ ឥឡូវនេះ សូមទូលព្រះជាម្ចាស់ពីរបៀប ដែលអ្នកត្រូវឆ្លើយតបចំពោះព្រះហឫទ័យប្រណីសន្តោស ដែលកំពុងកែប្រែជីវិតរបស់អ្នកនេះ ។ សូមអធិស្ឋាន... » ។

សូមសរសេរសេចក្តីត្រូវការរបស់ក្រុមជំនុំអ្នក អោយបានបីយ៉ាងខាងក្រោមនេះ :

១- _____

_____

_____

_____

_____

២- _____

_____

_____

_____

_____

_____

៣- _____

_____

_____

_____

_____

៤ - សិក្សាព្រះគម្ពីរ

គ្រូអធិប្បាយត្រូវអានព្រះគម្ពីររាល់ថ្ងៃ ដើម្បីអោយស្គាល់ខព្រះគម្ពីរ និង ប្រធានបទទាំងអស់នៅក្នុងព្រះគម្ពីរច្បាស់ ។ គ្រូអធិប្បាយដែលសិក្សាព្រះគម្ពីររាល់ថ្ងៃ មិនខ្វះគំនិតសំរាប់អធិប្បាយទេ ។ គ្រូគង្វាលត្រូវចេះព្រះគម្ពីរទាំងមូល ដើម្បីអាចជ្រើសយកខគម្ពីរដែលសំដែងពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះអ្វីៗ និង ដែលក្រុមជំនុំរបស់គាត់ត្រូវការ ដូចជា ការកែប្រែចិត្តគំនិត ជំនឿ សេចក្តីស្រឡាញ់ចំពោះអ្នកដទៃ ការអត់ទោស សេចក្តីសង្ឃឹម ។ល។ ។ ព្រះគម្ពីរជាប្រភព និង ជាគ្រឹះនៃសេចក្តីអធិប្បាយរបស់គ្រូអធិប្បាយ ។



៨ - រៀបចំលំនាំដើម

(សេចក្តីផ្តើម)

សេចក្តីផ្តើមបញ្ជាក់អំពីសារៈសំខាន់ និង គោលដៅរបស់ប្រធានបទ ។ ឧទាហរណ៍ សេចក្តីអធិប្បាយអំពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ អាចចាប់ផ្តើមដូចនេះ «តើអ្នកដែលសង្ស័យចំពោះសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែរឬទេ ? បើសិនជាមនុស្សម្នាក់រត់ចូលក្នុងផ្ទះដែលកំពុងតែមានភ្លើងឆេះ ដើម្បីសង្គ្រោះអ្នកពីក្នុងភ្លើង តើអ្នកសង្ស័យថា អ្នកនោះមិនស្រឡាញ់អ្នកដែរឬទេ ? តើមានភស្តុតាងបញ្ជាក់ថា ព្រះជាម្ចាស់ស្រឡាញ់អ្នកដែរឬទេ ? ព្រះជាម្ចាស់បានបូជាព្រះបុត្រារបស់ព្រះអង្គ ដើម្បីសង្គ្រោះយើង អោយរួចពីភ្លើងនៃអំពើបាប និង សេចក្តីស្លាប់ ។ ដូច្នេះ ថ្ងៃនេះ យើងនឹងសិក្សាពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់នៅក្នុងបទគម្ពីរ អេភេសូ ២:១-១០ ។

នេះជាឧទាហរណ៍អំពីការប្រើឧទាហរណ៍បំភ្លឺ ដែលពន្យល់អំពីរបៀបដែលព្រះយេស៊ូជា «ផ្លូវ» សំរាប់យើង ។ ផ្លូវជួយយើងឱ្យអាចធ្វើដំណើរពីកន្លែងដែលយើងនៅ ទៅកន្លែងផ្សេងទៀតដែលយើងចង់ទៅ ។ បើយើងចង់ធ្វើដំណើរពីភ្នំពេញ ទៅទិសខាងជើងដើម្បីទៅបាត់ដំបង យើងមិនមែនធ្វើដំណើរ តាមផ្លូវទៅត្បូងដែលទៅកំពង់សោមទេ ។ ព្រះយេស៊ូជាផ្លូវតែមួយគត់ ដែលនាំយើងអោយទៅដល់ព្រះបិតា ។ ព្រះគម្ពីរចែងថា÷ *«ព្រះយេស៊ូជាផ្លូវ»* ។ លើសពីនេះទៅទៀត ព្រះគម្ពីរចែងប្រាប់យើងថា ព្រះយេស៊ូជាស្ពានមេត្រីរវាងព្រះជាម្ចាស់ និង មនុស្ស (យ៉ូហាន ១៤:៦, ១ ធីម៉ូថេ ២:៥-៦) ។

សូមសរសេរឧទាហរណ៍បំភ្លឺផ្សេងមួយទៀត ដែលពន្យល់ពីរបៀបដែលព្រះយេស៊ូជា «សេចក្តីពិត» ។

_____

_____

_____

៥ - ជ្រើសរើសអត្ថបទ

(វគ្គព្រះគម្ពីរ)

យើងជ្រើសយកវគ្គព្រះគម្ពីរមួយ ដែលត្រូវនឹងសេចក្តីត្រូវការនៃក្រុមជំនុំ ។

យូរៗម្តង យើងបង្រៀនសៀវភៅរបស់ព្រះគម្ពីរណាមួយទាំងមូល ។ ក្នុងករណីនេះ ត្រូវជ្រើសរើសសៀវភៅព្រះគម្ពីរមួយ ហើយបែងចែកជាច្រើនផ្នែក ។ សូមបង្រៀនសៀវភៅនេះ ដោយអធិប្បាយផ្នែកនិមួយៗតាមលំដាប់លំដោយ ។

តើអ្នកដែលអធិប្បាយបន្តបន្ទាប់ អំពីផ្នែកផ្សេងៗនៃសៀវភៅណាមួយរបស់ព្រះគម្ពីរដែរឬទេ ? ។ _____

សូមផ្លាស់ប្តូរសេចក្តីអធិប្បាយរបស់អ្នក ។ បើអធិប្បាយពីសៀវភៅតែមួយជាប់ៗគ្នាក្នុងរយៈពេលយូរ អាចនាំអោយអ្នកស្តាប់ធុញទ្រាន់ ។ ការដែលអ្នកអធិប្បាយពីសេចក្តីផ្សេងៗទៀត យូរៗម្តង នៅចន្លោះផ្នែកផ្សេងៗនៃកម្រងសេចក្តីអធិប្បាយរបស់ប្រធានបទទាំងនោះ ជាការប្រសើរ ។

តាមធម្មតា គួរតែធ្វើសេចក្តីអធិប្បាយពីវគ្គព្រះគម្ពីរតែមួយ ។ ធ្វើដូចនេះ នឹងបានលទ្ធផលល្អជាងធ្វើសេចក្តីអធិប្បាយពីវគ្គព្រះគម្ពីរច្រើនដែលដកស្រង់ពីសៀវភៅផ្សេងៗ ។ បើសិនជាអ្នកមិនដឹងថា អត្ថបទគម្ពីរណាត្រូវសំរាប់គោលដៅរបស់អ្នកទេ សូមមើលក្នុងវចនានុក្រមរបស់ព្រះគម្ពីរ ឬ ក្នុងសៀវភៅសមោធាន ឬ ក្នុងសៀវភៅកំណត់របស់អ្នកផ្ទាល់ ។ គ្រូបង្ហាត់អ្នកក៏អាចប្រាប់អ្នកអំពីអត្ថបទណាមួយដែរ ។

ត្រូវអធិស្ឋាន និង សិក្សាព្រះគម្ពីរ ដើម្បីអោយព្រះជាម្ចាស់បង្ហាញអ្នកពីសេចក្តីត្រូវការរបស់ក្រុមជំនុំ ឬ ពីឱកាសសំរាប់ឱ្យក្រុមជំនុំរបស់អ្នកបំរើអ្នកដទៃ ។

សូមសរសេរអត្ថបទព្រះគម្ពីរមួយ (ជំពូក និង ខ) ដែលត្រូវនឹងកិច្ចការនេះ :

_____

_____

យើងត្រូវពន្យល់បញ្ជាក់អោយបានច្បាស់លាស់ ដោយប្រើ :

- រឿងក្នុងព្រះគម្ពីរ
- ឧទាហរណ៍បំភ្លឺ
- ពាក្យរំលឹកដាស់តឿន
- កំណាព្យ
- ផែនទី
- រូបភាព
- ការប្រៀបធៀប
- ឧទាហរណ៍ (បញ្ជាំងវីដេអូ គួររួប សំដែងល្ខោន ។ល។)
- គំនូរ
- សំនួរ ។ល។ ។

© Project WorldReach © SEAN

៦ - រកគោលគំនិត/ ចំណុចសំខាន់ៗរបស់អត្ថបទ ព្រះគម្ពីរ ដែលលោកអ្នកបានជ្រើសរើស

សូមសិក្សាអត្ថបទដែលអ្នកត្រូវអធិប្បាយ យ៉ាងល្អិតល្អន់ ។

តើសមាជិករបស់អ្នក ត្រូវយល់ដឹងអំពីសេចក្តីពិតសំខាន់ៗណាខ្លះ ? តាមរយៈអត្ថបទនេះ តើព្រះជាម្ចាស់បង្រៀនយើងពីសេចក្តីសំខាន់ៗអ្វីខ្លះទៀត ? ។

ឧទាហរណ៍ :

យ៉ូហាន ៣:១៦

១- ព្រះជាម្ចាស់ស្រឡាញ់យើង ។

២- ព្រះអង្គប្រទានព្រះបុត្រាព្រះអង្គ ដើម្បីយើង ។

៣- យើងត្រូវជឿលើព្រះអង្គ ។

៤- ព្រះអង្គប្រទានជីវិតអស់កល្បអោយអស់អ្នកណាដែលជឿ គឺមិនដាក់ទោសអ្នកជឿទាំងអស់នោះ ។



៧ - រៀបចំសេចក្តីអធិប្បាយអំពី ប្រធានបទ ដែលបានជ្រើសរើស

(បកស្រាយ ពន្យល់បំភ្លឺ និង ធ្វើអោយទាក់ទងនឹងជីវិតអ្នកស្តាប់)

បកស្រាយ ឬ ពន្យល់អោយគេយល់ច្បាស់ពីគោលគំនិតសំខាន់ៗនិមួយៗនៃគម្រោងរបស់អ្នក ដោយរបៀបបីយ៉ាង :

- ពន្យល់គោលគំនិតសំខាន់ៗទាំងនោះ អោយច្បាស់លាស់ ។
- បំភ្លឺដោយឧទាហរណ៍ (ដកស្រង់ឧទាហរណ៍ពីព្រះគម្ពីរ ឬ ពីជីវិតរស់នៅប្រចាំថ្ងៃ ឬ ធ្វើការប្រៀបធៀបដូចជាប្រស្នារបស់ព្រះអម្ចាស់យេស៊ូ) ។
- ធ្វើឱ្យការអធិប្បាយទាក់ទងទៅនឹងជីវិតរបស់ពួកអ្នក ដែលកំពុងស្តាប់) ។



សូមសរសេរសេចក្តីសំខាន់ៗបំផុត ។

រ៉ូម ៥:១២ ចែងថា÷ *«តាមរយៈមនុស្សតែម្នាក់ បាបបានចូលមកក្នុងពិភពលោក ហើយតាមរយៈបាប សេចក្តីស្លាប់ក៏ចូលមកដែរ ។ ហេតុនេះហើយបានជាសេចក្តីស្លាប់រាលដាលដល់មនុស្សគ្រប់រូប ព្រោះគ្រប់គ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប »* ។

អ្នកអាចកត់សំគាល់គោលគំនិតសំខាន់ជាច្រើន ។ ប៉ុន្តែ តើគោលគំនិតសំខាន់ណាខ្លះ ដែលជួយកសាងក្រុមជំនុំរបស់អ្នកជាងគេ ? សូមអានអត្ថបទនេះម្តងទៀត ។

យើងអាចបញ្ជាក់ពី :

- អំពើបាបចូលមកតាមរយៈលោកអ័ដាម ។
- អំពើបាបនាំអោយមានសេចក្តីស្លាប់ ។
- អំពើបាប និង សេចក្តីស្លាប់រាលដាលដល់មនុស្សគ្រប់រូប ។

ព្រះយេស៊ូមានបន្ទូលឆ្លើយថា÷ *«ខ្ញុំហ្នឹងហើយជាផ្លូវ ជាសេចក្តីពិត និង ជាជីវិត ។ គ្មាននរណាម្នាក់អាចទៅកាន់ព្រះបិតាបានឡើយ លើកលែងតែទៅតាមរយៈខ្ញុំ »* ។

តើប្រធានបទរបស់អត្ថបទនេះ គឺអ្វី ? ។

សូមប្រើខគម្ពីរនេះ ដើម្បីធ្វើគម្រោង ដែលមានគោលគំនិតសំខាន់ពីរ ឬ បី ឬ បួន ដែលអ្នកអាចរកឃើញ យោងទៅតាមប្រធានបទនេះ ។

© Project WorldReach © SEAN

- ការទូលសូមអោយមានជ័យជំនះខាងព្រលឹងវិញ្ញាណ (សូមកុំបណ្តោយយើងខ្ញុំអោយចាញ់ការល្បួងឡើយ តែសូមរំដោះយើងខ្ញុំអោយរួចពីមារកំណាចវិញ) ។
- ការសរសើរតម្កើង (ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព និង សិរីរុងរឿងអស់កល្បជាអង្វែងតរៀងទៅ) ។

នេះគ្រាន់តែជាឧទាហរណ៍ទេ តែអ្នកអាចរកឃើញគោលគំនិតសំខាន់ផ្សេងៗទៀត ។

ឥឡូវនេះ សូមសរសេរគម្រោងអំពីបទគម្ពីរ យ៉ូហាន ១៤:៦ :

សូមអាន អេភេសូ ២:៨-១០ ។ តើអ្នកឃើញមានសេចក្តីអ្វីខ្លះដែលទាក់ទងនឹងសេចក្តីសង្គ្រោះ ? ។ យើងអាចឃើញគោលគំនិតសំខាន់ខាងក្រោមនេះ :

- យើងបានសង្គ្រោះ ដោយសារព្រះអង្គមានព្រះហឫទ័យប្រណីសន្តោស (ខ ៨) ។
- យើងបានសង្គ្រោះ ដោយសារជំនឿ (ខ ៨) ។
- យើងបានសង្គ្រោះ មិនមែនមកពីយើងបានប្រព្រឹត្តអំពើល្អនោះទេ (ខ ៩) ។
- អំពើល្អជាលទ្ធផលដែលត្រូវតែកើតមានជាចាំបាច់ ដោយសារការសង្គ្រោះ (ខ ១០) ។

គម្រោងនៅទំព័របន្ទាប់នេះ បង្ហាញពីរបៀបរកសេចក្តីពិតសំខាន់ៗរបស់អត្ថបទព្រះគម្ពីរ (គម្រោងត្រូវមានសេចក្តីសង្ខេបនៃវគ្គព្រះគម្ពីរ ប្រធានបទ និង គោលគំនិតសំខាន់ៗ) ។

ការកែប្រែចិត្តគំនិត - លូកា ១៩:១-១០

- លោកសាខេខំស្វែងរកព្រះយេស៊ូ (ខ ១-៤) ។
- លោកសាខេជួប ហើយទទួលស្គាល់ព្រះយេស៊ូ (ខ ៥-៧) ។
- លោកសាខេទទួលជឿព្រះគ្រីស្ត ហើយកែប្រែចិត្តគំនិត (ខ ៨-១០) ។

ពិធីកាច់នំប៉័ង - ១ កូរិនថូស ១១:២៣-២៦

- ជាសេចក្តីបង្គាប់របស់ព្រះគ្រីស្ត (ខ ២៣) ។
- ជាការរំលឹកអំពីព្រះអង្គ (ខ ២៤) ។
- ជាសញ្ញាសំគាល់អំពីសម្ពន្ធមេត្រីថ្មី (ខ ២៥) ។

ការសង្គ្រោះអស់អ្នកដែលបាត់បង់ - លូកា ១៥:១១-៣២

- កូនពៅវង្វេងបាត់ទៅ (ខ ១១-១៣) ។
- កូនពៅយល់ដឹងពីកំហុសរបស់ខ្លួន (ខ ១៤-១៧) ។
- កូនពៅកែប្រែចិត្តគំនិត (ខ ១៨-១៩) ។
- កូនពៅវិលមកជានានឹងឪពុកវិញ (ខ ២០-២៤) ។

ការអធិស្ឋាន - ម៉ាថាយ ៦:៩-១៣

សេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់ បង្រៀនយើងអំពីចំណុចផ្សេងៗ នៃការអធិស្ឋាន ដូចខាងក្រោមនេះ :

- ការរួបរួមជាមួយព្រះជាម្ចាស់ (ឱ ព្រះបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !) ។
- ការថ្វាយបង្គំ (សូមសំដែងបារមីអោយមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ) ។
- ការទូលសូមអោយព្រះរាជ្យរបស់ព្រះជាម្ចាស់រីកសាយ កាន់តែខ្លាំង (សូមអោយព្រះរាជ្យព្រះអង្គបានមកដល់ សូមឱ្យព្រះហឫទ័យរបស់ព្រះអង្គបានសំរេច នៅលើផែនដី ដូចនៅស្ថានបរមសុខដែរ) ។
- ការទូលសូម (សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ) ។
- ការលន់តួសារភាព (សូមអត់ទោសឱ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសអោយអស់អ្នក ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ) ។